# ឯកសារសង្ខេបអំពីដៃគូយុទ្ធសាស្ត្រអនុវត្តន៍កម្មវិធី
# ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

## សេចក្តីសង្ខេបគម្រោង

គម្រោងលើកកម្ពស់ការទទួលបានសេវាដែលមាននិរន្តរភាព នឹងអនុវត្តឡើងក្នុងគោលបំណងដើម្បីពង្រឹងសិទ្ធិអំណាច និងកសាងសមត្ថភាពដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងស្រុកគោលដៅ ដើម្បីពួកគាត់អាចទាមទារសិទ្ធិក្នុងការទទួលបាននូវសេវាដែលមានគុណភាព និងប្រកបដោយបរិយាបន្ន។ គម្រោងនេះនឹងកសាងសមត្ថភាពដល់មន្ត្រីមានកាតព្វកិច្ច/អ្នកផ្តល់សេវា ដើម្បីបង្កើនចំណេះដឹងរបស់ពួកគាត់អំពីសិទ្ធិស្ត្រី អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងគោលនយោបាយ និងគោលការណ៍ណែនាំផ្សេងៗ ដែលធ្វើឱ្យពួកគាត់បំពេញភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពក្នុងការផ្តល់សេវាកាន់តែទូលំទូលាយ ប្រកបដោយបរិយាបន្នដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងស្ត្រីនិងក្មេងស្រីដែលមានពិការភាព។

## លទ្ធផលគម្រោង

- បង្កើនសមត្ថភាពដល់មន្ត្រីមានកាតព្វកិច្ច/អ្នកផ្តល់សេវានៅក្នុងស្រុកគោលដៅ ដើម្បីអនុវត្តគោលនយោបាយស្តីពីអំពើហិង្សាលើស្ត្រី និងផ្តល់សេវាសំខាន់ៗដោយបង្កើនការចូលរួមពីស្ត្រីនិងក្មេងស្រីដែលមានពិការភាពប្រកបដោយបរិយាបន្ន។
- សម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ត្រី ក្មេងស្រី យុវជន និងបុគ្គលមានពិការភាព ដើម្បីស្វែងរកការគាំទ្រមតិសម្រាប់សកម្មភាពឆ្លើយតបពីមន្ត្រីមានកាតព្វកិច្ច/អ្នកផ្តល់សេវាទាក់ទងនឹងបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការបញ្ជូនសេវា។
- ធានាថាជនរងគ្រោះដោយអំពើហិង្សា រួមទាំងជនមានពិការភាព មានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានសេវាសំខាន់ៗ ប្រកបដោយគុណភាព និងបរិយាបន្ន រួមទាំងការគាំទ្រផ្នែកផ្លូវចិត្តសង្គម និងផ្លូវច្បាប់។
- បង្កើតយន្តការតាមដាន វាយតម្លៃ ស្រាវជ្រាវ និងសិក្សា ដើម្បីវាយតម្លៃ និងកែលម្អប្រសិទ្ធភាព និងលទ្ធផលគម្រោងជាបន្តបន្ទាប់។

**សកម្មភាពសំខាន់ៗ**

- បង្កើតក្រុមគាំទ្រស្ត្រី/យុវជននៅតាមស្រុកគោលដៅ ក្រុមទាំងនេះរួមមានសមាជិកដែលបានទទួលការបណ្តុះបណ្តាល ផ្តោតលើសិទ្ធិស្ត្រី និងសិទ្ធិជនមានពិការភាព សមភាពយេនឌ័រ និងជំនាញតស៊ូមតិ។ ក្រុមបង្កើនការយល់ដឹងអំពីហិង្សាទាក់ទងនឹងយេនឌ័រ រាយការណ៍ករណី និងចូលរួមជាមួយមន្ត្រីមានកាតព្វកិច្ច/អ្នកផ្តល់សេវាដើម្បីមានឥទ្ធិពលលើគោលនយោបាយ តាមរយៈកិច្ចប្រជុំប្រចាំត្រីមាស។
- ផ្តល់ភាពអង់អាចដល់ក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតាមស្រុកគោលដៅ ដើម្បីអនុវត្តគោលនយោបាយនានាពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីតាមរយៈការបណ្តុះបណ្តាលស្តីពីសមភាពយេនឌ័រ បរិយាបន្នពិការភាពសេវាសំខាន់ៗ និងច្បាប់។ លើសពីនេះ គម្រោងនឹងសាកល្បងរៀបចំបន្ទប់ពិគ្រោះយោបល់ និងពង្រឹងការសម្របសម្រួលជាមួយអង្គការដៃគូ។
- សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាគាំទ្រផ្នែកផ្លូវចិត្ត សង្គម និងផ្លូវច្បាប់ដល់ជនរងគ្រោះ និងពង្រីកសេវាមណ្ឌលសុវត្ថិភាពក្នុងទីក្រុងភ្នំពេញ និងខេត្តសៀមរាប ដោយផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន ជំនួយផ្នែកពេទ្យ ការប្រឹក្សាយោបល់ និងជំនួយផ្នែកច្បាប់។
- ចងក្រងឯកសារ រៀបចំការវាយតម្លៃជាទៀងទាត់ និងកិច្ចប្រជុំ ដោយលើកឡើងនូវឧបសគ្គ និងការអនុវត្តល្អៗដោយផ្តោតលើសម្លេងពីសហគមន៍ ជាពិសេសសមាជិកក្រុមស្ត្រី រួមទាំងស្ត្រី និងក្មេងស្រីដែលមានពិការភាព។

**អ្នកទទួលផល**

**ក្រុមគោលដៅផ្ទាល់៖** ស្ត្រី និងក្មេងស្រីរួមទាំងស្ត្រី និងក្មេងស្រីដែលមានពិការភាព ដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងមានហានិភ័យនៃអំពើហិង្សាលើស្ត្រី ។

**ក្រុមគោលដៅមិនផ្ទាល់៖** សមាជិករបស់ក្រុមការងារឆ្លើយតបអំពើហឹង្សាទាក់ទងនឹងយេនឌ័រ សមាជិករបស់ក្រុមគាំទ្រស្ត្រី/យុវជន និងសហគមន៏ ដៃគូអង្គការមិនមែនរដ្ឋាភិបាល ដៃគ ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្តដែលគាំទ្រគម្រោង។

**ទីតាំងភូមិសាស្ត្រ**

គម្រោងអនុវត្តក្នុងខេត្តចំនួនពីរ៖ ស្រុកស្វាយលើក្នុងខេត្តសៀមរាប និងស្រុកសាមគ្គីមុនីជ័យក្នុងខេត្តកំពង់ស្ពឺ

**ដៃគូអនុវត្តគម្រោង**

ក្រសួងរកិច្ចការនារី មន្ទីរកិច្ចការនារី ក្រសួងង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បាទា មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បាទា ក្រសួងយុត្តិធម៌ និងតុលាការខេត្ត។ល។

| | |
|---|---|
| កិច្ចសហការជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដែលអង្គាការស្រ្តីកម្ពុជាដើម្បីជួយស្រ្តីមានវិបត្តិ មានកិច្ចសហការល្អកន្លងមក តាមរយៈគម្រោង ACCESS ដំណាក់កាលទី១ មានដូចជា មន្ទីរកិច្ចការនារីក្នុងខេត្តកំពង់ស្ពឺ និងខេត្តសៀមរាប ក្រុមការងារឆ្លើយតបអំពើហឹង្សាទាក់ទងនឹងយេនឌ័រ អង្គការ UN Women  អង្គការ UNFPA អង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) អង្គការ CARE Cambodia អង្គការ ADD International និងដៃគូការងារផ្នែកពិការភាព ។ | |
| **រយៈពេលអនុវត្តគម្រោង** | |
| ខែមករា ឆ្នាំ២០២៤ ដល់ខែធ្នូ ឆ្នាំ២០២៧ | |
| **ទំនាក់ទំនង** | |
| អង្គការកម្ពុជាដើម្បីជួយស្រ្តីមានវិបត្តិ (CWCC)<br>លោកស្រី ចាក់ សុជាតិ<br>នាយិកាប្រតិបត្តិ<br>ទូរសព្ទលេខ៖ (៨៥៥) ១២ ២៣៩ ៩១០<br>អ៊ីម៉ែល: director@cwcc.org.kh | កម្មវិធី ACCESS<br>អ្នកស្រី ប៊ូ មករា<br>ប្រធានផ្នែកអំពើហឹង្សាទាក់ទងនឹងយេនឌ័រ (GBV)<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៦៩៤ ៩៩៤<br>អ៊ីម៉ែល៖ makara.bou@access2cambodia.org |

គម្រោងនេះគាំទ្រថវិការដោយរដ្ឋាភិបាលអូស្រ្តាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្រ្តាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី ២ (ACCESS 2) ។

ខែមីនា ឆ្នាំ២០២៤